# កូល៉ុស ១:១-១៤

អ្នកនិពន្ធ រុហ្វ លេភិឡារ

## សេចក្តីណែនាំ

ប៉ុលបានយកចិត្តទុកដាក់អំពីឥទ្ធិពលរបស់សាសនាខុសឆ្គងមកលើពួកជំនុំកូល៉ុស។ បច្ចុប្បន្នកាលមានមនុស្សជាច្រើន ដូចជាអ្នកខ្លះនៅក្នុងក្រុងកូល៉ុសដែរ ទទួលយកសេចក្តីពិត*ខ្លះ*អំពីព្រះយេស៊ូវ (ឧទាហរណ៍ ទ្រង់គឺជាគ្រូបង្រៀនដ៏ល្អម្នាក់ដែលយើងគួរគោរព ឬទ្រង់គឺជាហោរាម្នាក់…ល) ប៉ុន្តែពួកគេនឹងមិនផ្តល់ឲ្យព្រះយេស៊ូវនូវកិត្តិនាមដែលទ្រង់សមនឹងទទួលក្នុងនាមជាព្រះរាជបុត្រានៃព្រះ ដែលជាព្រះអម្ចាស់លើទាំងអស់នោះឡើយ។ សេចក្តីជំនឿខុសឆ្គងអំពីព្រះយេស៊ូវនេះគឺជាគ្រោះថ្នាក់មួយនៅក្នុងក្រុងកូល៉ុស។ មនុស្សជារឿយៗបូកបញ្ចូលគំនិតផ្សេងៗពីសាសនាខុសៗគ្នា ហើយនៅក្នុងសតវត្សទីមួយ ក៏ដូចជាសព្វថ្ងៃនេះ មានសេចក្តីល្បួងឲ្យបូកបញ្ចូលព្រះយេស៊ូវជាមួយនឹងវិញ្ញាណ ព្រះ និងទេវតាផ្សេងៗ…ល។ មូលហេតុដែលប៉ុលបានសរសេរសំបុត្រនេះគឺដោយសារពួកកូល៉ុសកំពុងត្រូវបានល្បួងឲ្យលែងស្តាប់ «ព្រះបន្ទូលដ៏ពិត» (១:៥) ហើយបែរជាស្តាប់ «ពាក្យលួងលោម» [ពាក្យអន្ទង ឬពាក្យបបួល] (២:៤)។ ដូច្នេះ នៅក្នុងកូល៉ុសជំពូកមួយ ប៉ុលបង្រៀនអំពីឧត្តមភាពរបស់ព្រះគ្រីស្ទ។

**ខគម្ពីរគន្លឹះក្នុងកូល៉ុស៖** កូល៉ុស ២:៦-៧ គឺជាខគម្ពីរគន្លឹះនៅក្នុងកណ្ឌគម្ពីរកូល៉ុស។ ២:៦-៧ បញ្ជាក់អំពីគោលបំណងដែលប៉ុលសរសេរសំបុត្រនេះ។

**គំនិតចំបងនៅក្នុងជំពូកមួយ៖** ព្រះយេស៊ូវពិតជាធំខ្ពស់និងគ្រប់គ្រាន់ (យើងមិនចាំបាច់បន្ថែមព្រះ/វិញ្ញាណផ្សេងៗទៀត …ល. ទៅលើព្រះយេស៊ូវដើម្បីឲ្យបានចំណេះដឹងពេញលេញអំពីព្រះនោះឡើយ)។ ទ្រង់ពិសេសដាច់ដោយឡែកនិងធំខ្ពស់នៅក្នុងការងារបង្កបង្កើតនិងសេចក្តីប្រោសលោះរបស់ទ្រង់។

## អត្ថាធិប្បាយ

**ខ. ១-២** នៅទីនេះប៉ុលប្រើទំរង់ស្តង់ដានៃការចាប់ផ្តើមសំបុត្រ។ ទំរង់ស្តង់ដានេះមានការជំរាបសួរ ការអរព្រះគុណ និងសេចក្តីអធិស្ឋាន។ នៅទីនេះការជំរាបសួរគឺមកពីទាំងប៉ុលនិងធីម៉ូថេផង។ ទាំងការត្រាស់ហៅនិងព័ន្ធកិច្ចរបស់ប៉ុលគឺដោយនូវព្រះហឫទ័យព្រះ ដែលបង្ហាញថា គឺវាមកពីព្រះគុណរបស់ព្រះតែមួយគត់ ហើយថា ប៉ុលបានមានទំនួលខុសត្រូវពិសេសមួយ។ ធីម៉ូថេគឺជាគូកនរបស់ប៉ុល។ ធីម៉ូថេបានទទួលជឿព្រះគ្រីស្ទតាមរយៈប៉ុល (១ធីម៉ូថេ ១:២) ប៉ុន្តែប៉ុលបានហៅគាត់ថា «បងប្អូនយើងខ្ញុំ» ដូច្នេះ យើងមើលឃើញភាពស្មើគ្នារបស់ពួកអ្នកជឿទាំងអស់នៅក្នុងព្រះគ្រីស្ទ។ ប៉ុលហៅពួកកូល៉ុសថា បរិសុទ្ធ។ គ្រីស្ទបរិស័ទទាំងអស់គឺបរិសុទ្ធ ពីព្រោះព្រះបានធ្វើឲ្យពួកគេបរិសុទ្ធ។ «ព្រះដ៏ជាព្រះ វរបិតានៃយើងរាល់គ្នា» មិនកំពុងសំដៅថាព្រះជាព្រះវរបិតានៃមនុស្សទាំងអស់នោះទេ ប៉ុន្តែទ្រង់ជាព្រះវរបិតានៃអស់អ្នកដែលទ្រង់បានទទួលយកជាកូនចិញ្ចឹមតាមរយៈព្រះយេស៊ូវតែប៉ុណ្ណោះ។ ខ. ២ «ព្រះគុណនិងសេចក្តីសុខសាន្ត» ព្រះគុណនិងសេចក្តីសុខសាន្តរបស់ព្រះមានប្រភពមកពីការស្គាល់អំណាចនៃដំណឹងល្អ។

### ប៉ុលមានអំណរក្នុងផលផ្លែរបស់ដំណឹងល្អ (ខ. ៣-៨)

**ខ. ៣-៦** ប៉ុលមិនដែលបានជួបពួកកូល៉ុសទេ ប៉ុន្តែគាត់បានឮដំណឹងល្អអំពីការប្តេជ្ញាចិត្តរបស់ពួកគេចំពោះព្រះគ្រីស្ទ ដូច្នេះហើយគាត់ជឿថា ពួកគេគឺជាពួកគ្រីស្ទបរិស័ទពិតប្រាកដ ពីព្រោះគាត់បានឮសេចក្តីរាយការណ៍ (ប្រហែលតាមរយៈអេប៉ាប្រាស) អំពីសេចក្តីជំនឿ សេចក្តីស្រលាញ់ និងសេចក្តីសង្ឃឹមរបស់ពួកគេ (ខ. ៣-៤) ប្រៀបធៀប៖ (រ៉ូម ៥:២-៥, ១កូរិនថូស ១៣:១៣, ១ថែស្សាឡូនិច ១:៣)។ ជារឿយៗមនុស្សអរព្រះគុណដល់ព្រះដោយសារអ្វីដែលទ្រង់បានធ្វើនៅក្នុងជីវិត

របស់ពួកគេផ្ទាល់ ប៉ុន្តែប៉ុលអរព្រះគុណដល់ព្រះដោយសារអ្វីដែលទ្រង់បានធ្វើនៅក្នុងជីវិតអ្នកដទៃវិញ (ពួកកូល៉ុស)។ ការអរព្រះគុណគឺជាផ្ទៃរឿងរួមមួយនៅក្នុងកណ្ឌគម្ពីរកូល៉ុស (១:១២, ២:៧, ៣:១៥, ១៧, ៤:២)។

ពួកគ្រូខុសឆ្គងដែលពួកកូល៉ុសត្រូវបានល្បួងឲ្យដើរតាម បានមានសារមួយ ប៉ុន្តែសារនោះមិនមានអំណាចនោះទេ។ ពួកគេបានបង្រៀនអំពីពួកទេវតា ការបើកសំដែងពីព្រះ ច្បាប់ និងសេចក្ដីបញ្ញត្តសំរាប់រូបកាយ ប៉ុន្តែសាររបស់ពួកគេមិនមានអំណាចដើម្បីផ្លាស់ប្រែជីវិតឡើយ (២:២០-២៣)។ នៅក្នុង១:៣-៦ ប៉ុលថ្លែងអំពីលទ្ធផលដែលដំណឹងល្អរបស់ព្រះគ្រីស្ទបានមានលើពួកកូល៉ុស។ សាសនារបស់មនុស្សមិនអាចផ្លាស់ប្ដូរជីវិតរបស់ពួកគេដើម្បីឲ្យពួកគេមានសេចក្ដីជំនឿ សេចក្ដីសង្ឃឹម និងសេចក្ដីស្រលាញ់បានឡើយ ប៉ុន្តែដំណឹងល្អអាចធ្វើការនេះបាន។ មានតែព្រះយេស៊ូវគ្រីស្ទប៉ុណ្ណោះដែលអាចប្រទានសេចក្ដីជំនឿ ផ្លាស់ប្ដូរចិត្តអាត្មានិយមឲ្យទៅជាចិត្តដែលមានសេចក្ដីស្រលាញ់ ហើយប្រទានសេចក្ដីសង្ឃឹមសំរាប់ពេលអនាគត។ សូមកត់សំគាល់ថា ពួកគេមានសេចក្ដីស្រលាញ់ចំពោះពួកបរិសុទ្ធ*ទាំងអស់* មិនគ្រាន់តែអស់អ្នកដែលមានជាតិសាសន៍ អាយុ ភេទ ឬឋានៈដូចគ្នានោះទេ។ ព្រះបន្ទូលរបស់ព្រះបានបង្កើតផលផ្លែនៅក្នុងជីវិតរបស់ពួកគេ ហើយផលផ្លែនេះគឺជាភស្តុតាងបង្ហាញអំពីសេចក្ដីសង្គ្រោះពិតប្រាកដ (ម៉ាថាយ ១៣:២៣, កាឡាទី ៥:៦, យ៉ាកុប ២:១៤..., ១យ៉ូហាន ៣:១៤)។ សូមកត់សំគាល់ផងដែរថា សេចក្ដីសង្ឃឹម «ដែលបំរុងទុកឲ្យអ្នករាល់គ្នានៅស្ថានសួគ៌»។ សេចក្ដីសង្ឃឹមគឺអំពីអនាគត ហើយអំពីព្រះបំពេញសំរេចសេចក្ដីសន្យារបស់ទ្រង់ចំពោះយើងនៅក្នុងព្រះគ្រីស្ទ (២កូរិនថូស ១:២០)។ ដូច្នេះដំណឹងល្អគឺមូលដ្ឋានគ្រឹះរបស់សេចក្ដីសង្ឃឹម (ខ. ៥ខ)។ ការជឿទុកចិត្តលើសេចក្ដីសន្យារបស់ព្រះនាំឲ្យយើងមានសង្ឃឹម។ ការបីយ៉ាងដែលយើងរៀនអំពីដំណឹងល្អនៅក្នុងខ. ៦ គឺថា

១. ដំណឹងល្អបង្កើតផលផ្លែពេញក្នុងលោកិយទាំងអស់

២. ដំណឹងល្អគឺជាព្រះរាជសារមួយដែលមនុស្សត្រូវតែស្ដាប់ឮ ហើយ

៣. ដំណឹងល្អបើកសំដែងអំពី «ព្រះគុណរបស់ព្រះ»។

សាររបស់ពួកគ្រូខុសឆ្គងមិនមែនជាសារអំពីព្រះគុណរបស់ព្រះនោះទេ ប៉ុន្តែជាប្រព័ន្ធច្បាប់និងប្រពៃណីរបស់មនុស្ស។ សូមកត់សំគាល់ថា ប៉ុលសរសេរថា គឺដំណឹងល្អទេដែលកំពុងរីកចំរើន។ ពួកគ្រីស្ទបរិស័ទសព្វថ្ងៃនេះជារឿយៗនិយាយអំពីការរីកចំរើនរបស់ពួកជំនុំ ប៉ុន្តែនៅទីនេះ ប៉ុលសរសេរអំពីការរីកចំរើន(ចំរើនឡើង)របស់ដំណឹងល្អ។ ការរីកចំរើនរបស់ដំណឹងល្អនាំឲ្យមានការរីកចំរើនរបស់ពួកជំនុំ ហើយការរីកចំរើនរបស់ពួកជំនុំណាដែលមិនមកពីការរីកចំរើនរបស់ដំណឹងល្អ មិនមែនជាការរីកចំរើនរបស់ពួកជំនុំពិតប្រាកដនោះឡើយ។

> *កំណត់សំគាល់៖* នៅក្នុងខ. ៣ ប៉ុលប្រើពាក្យ «ជានិច្ច»។ ព្រះគម្ពីរ គខប ដាក់ «ជានិច្ច» ជាមួយ «អរព្រះគុណព្រះជាម្ចាស់» (ដូចជាព្រះគម្ពីរភាសាអង់គ្លេស NIV និង RSV ដែរ)។ ការបកប្រែជាច្រើន ដូចជាព្រះគម្ពីរខ្មែរបរិសុទ្ធ ដាក់ «ជានិច្ច» ជាមួយ «*ក៏អធិស្ឋានឲ្យអ្នករាល់គ្នា*»។ នេះដោយព្រោះភាសាក្រិក «ជានិច្ច» អាចនៅជាមួយឃ្លាណាក៏បាន ប៉ុន្តែអ្នកបកប្រែភាគច្រើនជ្រើសរើសយកដាក់ «ជានិច្ច» ជាមួយ «*ក៏អធិស្ឋានឲ្យអ្នករាល់គ្នា*»។

**ខ. ៧-៨** ប៉ុលមិនបានមកសួរសុខទុក្ខពួកជំនុំនេះ ដោយផ្ទាល់ទេ (១:៩, ២:១) ប៉ុន្តែគាត់បានឮ (ប្រហែលពីអេប៉ាប្រាស) អំពីដំណឹងល្អនៃសេចក្ដីសង្គ្រោះរបស់ពួកគេ (ខ. ៤, ៧)។ អេប៉ាប្រាសប្រហែលបានឮដំណឹងល្អពីប៉ុលនៅឯក្រុងអេភេសូរ ហើយបាននាំយកដំណឹងល្អត្រឡប់មកឯក្រុងកូល៉ុស។ ព្រះប្រទានព្រះរាជសាររបស់ទ្រង់តាមរយៈមនុស្សដែលប្រកាសអំពីព្រះរាជសារនោះ ដែលខុសពីសាសនាផ្សេងៗដែលមនុស្សព្យាយាមស្វែងរកសេចក្ដីពិតខាងវិញ្ញាណតាមរយៈការប្រព្រឹត្តនិងពិធីបុណ្យសាសនានានារបស់ពួកគេ។ អេប៉ាប្រាសបានផ្ដល់ឲ្យពួកគេនូវ «ព្រះបន្ទូលដ៏ពិតនៃដំណឹងល្អ» (ខ. ៥) ផ្ទុយពី

សេចក្តីកុហករបស់គតិលោកដែលពួកគេបានកំពុងត្រូវល្បួងឲ្យដើរតាមនោះ។ សូមអរគុណដល់ព្រះសំរាប់ពួកគ្រូគង្វាល និងគ្រូបង្រៀនដំណឹងល្អស្មោះត្រង់ដែលប្រកាសសេចក្តីពិតមកកាន់ពួកយើង (សូមមើល ៤:១២)។

**ប៉ុលអធិស្ឋានឲ្យពួកគេ (ខ. ៩-១៤)**

**ខ. ៩-១១ក** «ហេតុនោះ»។ ការឮអំពីសេចក្តីជំនឿ សេចក្តីសង្ឃឹម និងសេចក្តីស្រលាញ់របស់ពួកកូល៉ុសនាំឲ្យលោកប៉ុលអធិស្ឋានឲ្យពួកគេឥតឈប់ឈរ ទោះបើគាត់មិនដែលបានជួបពួកគេក៏ដោយ។ តើការឮអំពីពួកគ្រីស្ទបរិស័ទផ្សេងទៀតនាំឲ្យអ្នកអធិស្ឋានឲ្យពួកគេដែរទេ? ប៉ុលបានអរព្រះគុណសំរាប់អ្វីដែលបានកើតឡើងចំពោះពួកគេរួចទៅហើយ។ គឺដោយសារតែអ្វីដែលព្រះបានធ្វើ*រួចរា*ល់ទៅ*ហើយ* នោះប៉ុលអាចអធិស្ឋានដោយមានទំនុកចិត្តសំរាប់អ្វីដែលព្រះ*នឹង*ធ្វើ។ ព្រះអង្គដែលបានចាប់ផ្តើមធ្វើការល្អនៅក្នុងពួកកូល៉ុស ទ្រង់ក៏នឹងបង្ហើយការនេះរហូតដល់ថ្ងៃព្រះគ្រិស្តយេស៊ូវយាងមក (សូមមើល ១កូរិនថូស ១:៨-៩, ភីលីព ១:៦)។ ឥឡូវនេះប៉ុលអធិស្ឋានថាពួកគេនឹងរីកចំរើន។ សេចក្តីអធិស្ឋានរបស់ប៉ុលនៅទីនេះបង្រៀនយើងអំពីរបៀបអធិស្ឋានបានល្អ។ ពួកគ្រីស្ទបរិស័ទជារឿយៗអធិស្ឋានសំរាប់ការខាងលោកិយ (ឧទាហរណ៍ សុខភាព ការងារជាដើម ហើយសេចក្តីអធិស្ឋានអំពីរឿងទាំងនេះមិនខុសទេ) ប៉ុន្តែយើងមិនត្រូវភ្លេចការខាងវិញ្ញាណនោះឡើយ។ ប៉ុលអធិស្ឋាននៅទីនេះសំរាប់ការខាងវិញ្ញាណនិងស្ថានសួគ៌ ហើយបង្ហាញយើងអំពីអ្វីដែលសំខាន់បំផុត។ ប៉ុលអធិស្ឋានថា ពួកគេនឹងបានសព្វគ្រប់ (ខ. ៩) បានបង្កើតផល (ខ. ១០) និងស្មោះត្រង់ ( ខ. ១១)។

ពួកគ្រូខុសឆ្គងបាននិយាយថា ពួកគេមានប្រាជ្ញាពិសេសដែលប្រសើរជាង។ ពួកគេបានប្រើពាក្យដូចជា ចំណេះ ប្រាជ្ញា និងចំណេះខាងឯវិញ្ញាណ។ ដូច្នេះ ប៉ុលបានប្រើពាក្យទាំងនេះនៅក្នុងសេចក្តីអធិស្ឋានរបស់គាត់។ សេចក្តីអធិស្ឋាននេះបានទូលសូមថា «សូម ឱ្យអ្នករាល់គ្នាបានស្គាល់ព្រះហឫទ័យទ្រង់សព្វគ្រប់ ដោយគ្រប់ទាំងប្រាជ្ញា និងចំណេះខាងឯវិញ្ញាណ»។ ពាក្យភាសាក្រិក πληροω (ដែលបកប្រែដោយ «សព្វគ្រប់»នៅទីនេះ) គឺជាពាក្យគន្លឹះនៅក្នុងកណ្ឌគម្ពីរកូល៉ុស។ វាក៏ជាពាក្យសំខាន់សំរាប់ពួកគ្រូខុសឆ្គងផងដែរ។ ប៉ុលបានប្រើពាក្យនេះនៅទីនេះ និងក្នុង១:១៩, ២៥, ២:២, ៩-១០, ៤:១២។ សេចក្តីអធិស្ឋានរបស់ប៉ុលគឺដើម្បីឲ្យពួកកូល៉ុសត្រូវបានគ្រប់គ្រងដោយចំណេះសព្វគ្រប់ក្នុងព្រះហឫទ័យព្រះ ដែលនឹងនាំមកឯការស្តាប់បង្គាប់។ យើងត្រូវបានធ្វើឲ្យ «ពេញលេញនៅក្នុងទ្រង់» (២:៩-១០) (ពាក្យ*ពេញលេញ* នៅទីនេះបកប្រែពាក្យភាសាក្រិកដែលមកពីពាក្យ πληροω) នៅទីនេះប៉ុលអធិស្ឋានថា ពួកគេអាចមានភាពពេញលេញនេះនៅក្នុងជីវិតរបស់ពួកគេ។ សូមកត់សំគាល់សំណូមដែលគាត់មានៈ

(១) ថាពួកគេអាចស្គាល់ព្រះហឫទ័យរបស់ទ្រង់

(២) ថាពួកគេនឹងដើរក្នុងផ្លូវដែលផ្គាប់ព្រះហឫទ័យព្រះ

(៣) ថាពួកគេនឹងធ្វើការដើម្បីបង្កើតផលផ្លែ

(៤) ថាពួកគេនឹងយល់ព្រះបន្ទូលបានប្រសើរឡើង ហើយ

(៥) ថាពួកគេនឹងស្គាល់អំណាចព្រះចេស្តាដែលពេញដោយសិរីល្អរបស់ទ្រង់។

យើងអាចរកព្រះពរទាំងនេះបានតែនៅក្នុងព្រះគ្រីស្ទប៉ុណ្ណោះ។ ការស្គាល់ព្រះហឫទ័យរបស់ទ្រង់មិនមានន័យថា យើងត្រូវតែស្វែងរកការសំរេចព្រះហឫទ័យរបស់ព្រះលើសេចក្តីលំអិតទាំងអស់នៅក្នុងជីវិតរបស់យើងនោះទេ ប៉ុន្តែមានន័យថា យើងនឹងដឹងអំពីរបៀបរស់នៅដែលផ្គាប់ព្រះហឫទ័យដល់ទ្រង់វិញ។ គោលបំណងដែលអំណាចព្រះចេស្តារបស់ព្រះធ្វើឲ្យយើងបានរឹងមាំគឺដើម្បីឲ្យយើងនឹងទ្រាំទ្រដោយអត់ធ្មត់។ ពេលខ្លះពួកគ្រីស្ទបរិស័ទនៅក្នុងលោកិយនេះប្រឈមនឹងបញ្ហាធំ ដូច្នេះយើងត្រូវការកំលាំងរបស់ព្រះដើម្បីទ្រាំទ្រដោយអត់ធ្មត់។ នេះគឺជាការល្អសំរាប់យើងអធិស្ឋានឲ្យពួកគ្រីស្ទបរិស័ទ។

**ខ. ១១ខ-១៤** ប៉ុលផ្ដល់ហេតុផលបួនដែលយើងគួរតែអរព្រះគុណដល់ព្រះ ដោយសារតែការទទួលចំណែកកេរ្ដិ៍អាករ សេចក្ដីសង្គ្រោះ ការផ្លាស់យើងមកក្នុងនគររបស់ទ្រង់ និងសេចក្ដីប្រោសលោះ/ សេចក្ដីអត់ទោសរបស់យើង។ យើងទទួលបានការទាំងនេះតាមរយៈព្រះគ្រីស្ទ ដូច្នេះ អ្វីៗដែលព្រះបានធ្វើសំរាប់យើងក្នុងព្រះគ្រីស្ទគឺជាមូលដ្ឋានគ្រឹះនៃការអរព្រះគុណរបស់យើងទៅចំពោះព្រះ។

ពាក្យ «សេចក្ដីប្រោសលោះ» ត្រូវបានគេប្រើនៅក្នុងសម័យបុរាណជាទូទៅសំដៅលើ «ការទិញពីទីផ្សារទាសករ»។ ទោះយ៉ាងណា សំរាប់ពួកយូដា ពាក្យនេះរំលឹកពួកគេអំពីពេលដែលព្រះបានប្រោសលោះរាស្ត្ររបស់ទ្រង់ចេញពីនគររបស់ស្ដេចផារ៉ោន។ សូមកត់សំគាល់នៅទីនេះថា ប៉ុលនិយាយថា សំរាប់ពួកគ្រីស្ទបរិស័ទ *សេចក្ដីប្រោសលោះគឺជាការអត់ទោសបាប (សេចក្ដីផ្ដាច់បាប)*។ យើងត្រូវការព្រះប្រោសលោះយើងចេញពីលទ្ធផលនៃអំពើបាបរបស់យើងផ្ទាល់។ ការសុគតរបស់ព្រះយេស៊ូវធ្វើឲ្យគាត់ខុសពីមនុស្សដទៃទាំងអស់នៅក្នុងប្រវត្តិសាស្ត្រ។ ពួកអ្នកដឹកនាំសាសនាបានស្លាប់ ប៉ុន្តែមានតែព្រះគ្រីស្ទប៉ុណ្ណោះដែលបានសុគតនៅលើឈើឆ្កាងសំរាប់អំពើបាបរបស់លោកិយដើម្បីប្រោសលោះយើង។ បទគម្ពីរនេះបង្រៀនយ៉ាងច្បាស់ថា ផ្លូវតែមួយដែលយើងអាចទទួលចំណែកកេរ្ដិ៍អាករនៅក្នុងនគរនៃពន្លឺគឺតាមរយៈការសុគតរបស់ព្រះយេស៊ូវ។ មនុស្សទាំងអស់ដែលនៅខាងក្រៅព្រះគ្រីស្ទ គឺកំពុងស្ថិតក្រោមអំណាចរបស់សេចក្ដីងងឹត។ វាមិនមែនជាការប្រព្រឹត្តរបស់យើងដែលយើងសមនឹងមានចំណែកក្នុង(គួរនឹងទទួលចំណែក) កេរ្ដិ៍អាកររបស់ពួកបរិសុទ្ធនោះទេ ប៉ុន្តែព្រះវរបិតារបស់យើងបានធ្វើឲ្យយើងសមនឹងទទួលបាន តាមរយៈការសុគតរបស់ព្រះយេស៊ូវ។ កេរ្ដិ៍អាករនៅក្នុងនគរនៃពន្លឺគឺជាអ្វីដែលយើងមានរួចទៅហើយ (ខ. ១២ យើងត្រូវបានសង្គ្រោះចេញពីសេចក្ដីងងឹតរួចទៅហើយ) ហើយជាអ្វីដែលយើងរង់ចាំដែលយើងនឹងទទួលបានវានៅអនាគតកាល។

> *កំណត់សំគាល់៖* នៅក្នុងបទគម្ពីរនេះប៉ុលប្រើពាក្យ «ដោយអំណរ»។ នៅក្នុងភាសាក្រិក វាមិនច្បាស់ថា *ដោយអំណរ* គួរតែត្រូវបានដាក់បញ្ចូលជាមួយ «ការទ្រាំទ្រនិងការអត់ធ្មត់» ដូចជានៅក្នុងព្រះគម្ពីរបរិសុទ្ធ (ហើយក្នុងព្រះគម្ពីរភាសាអង់គ្លេស KJV, ASV, RSV, NEB) ឬជាមួយ «ការអរព្រះគុណ» ដូចនៅក្នុងព្រះគម្ពីរគខប (ហើយក្នុងព្រះគម្ពីរភាសាអង់គ្លេស NIV) ដែរឬយ៉ាងណា។  តាមរបៀបណាក៏បាន គឺច្បាស់ណាស់ថា យើងគួរតែទ្រាំទ្រដោយអំណរ និងអរព្រះគុណដោយអំណរផងដែរ។

**ការអនុវត្តបញ្ចប់៖** យើងគួរតែអធិស្ឋានសេចក្ដីអធិស្ឋានរបស់ប៉ុលនៅក្នុងខ. ៩-១១ ឲ្យពួកគ្រីស្ទបរិស័ទដែលយើងស្គាល់។ អធិស្ឋានថា ពួកគ្រីស្ទបរិស័ទនឹងផ្គាប់ព្រះហឫទ័យព្រះនៅក្នុងគ្រប់ទាំងផ្លូវ ហើយព្រះសព្វព្រះទ័យនៅពេលពួកគ្រីស្ទបរិស័ទរីកចំរើនខាងចំណេះដឹងនិងអត្តចរិត ហើយនៅពេលពួកទ្រាំទ្រនិងបញ្ជាក់ការដឹងព្រះគុណសំរាប់សេចក្ដីសង្គ្រោះរបស់ពួកគេ។

## សំរាប់ការសិក្សាបន្ថែម

សូមសរសេរ «បញ្ជីសេចក្ដីអធិស្ឋាន» មួយដែលផ្អែកលើសេចក្ដីអធិស្ឋានរបស់ប៉ុលនិងអេប៉ាប្រាស (សូមមើល ១:៣, ៩-១១; ៤:១២; អេភេសូរ ៣:១៤-២១; ភីលីព ១:៩-១០)។

## សំនួរដែលត្រូវគិតពិចារណានិងពិភាក្សា

១. តើប៉ុលគួរតែនិយាយអ្វីនៅពេលគាត់ត្រូវសរសេរសេចក្តីរាយការណ៍អំពីពួកជំនុំរបស់អ្នក? តើគាត់អាចរាយការណ៍អំពី « សេចក្តីស្រលាញ់ដោយព្រះវិញ្ញាណ» ដូចជាអេប៉ាប្រាសបានរាយការណ៍អំពីពួកជំនុំនៅក្រុងកូល៉ុសដែរឬទេ (ខ. ៨)?

២. តើអ្វីគឺជាការសំខាន់បំផុតដែលយើងទូលសូមនៅក្នុងសេចក្តីអធិស្ឋាន? តើអ្នកអធិស្ឋានសំរាប់ការទាំងនេះឲ្យពួកគ្រីស្ទបរិស័ទដែរឬទេ? តើសេចក្តីអធិស្ឋានពេលថ្វាយបង្គំក្នុងពួកជំនុំអធិស្ឋានសំរាប់ការទាំងនេះដែរទេ?

៣. អេប៉ាប្រាសគឺជា «បាវបំរើស្ងួនភ្ងាជាមួយគ្នា» របស់ប៉ុល (ខ. ៧ក) ហើយគឺជាអ្នកបំរើស្មោះត្រង់របស់ព្រះគ្រីស្ទជំនួសឲ្យប៉ុល (ខ. ៧ខ)។ តើអ្នកមានអ្នកណានៅក្នុងជីវិតដែលជាបាវបំរើស្ងួនភ្ងារបស់ព្រះគ្រីស្ទជាមួយគ្នា?

### Bibliography


Anders, M. (1999). *Galatians-Colossians* (Vol. 8). Nashville, TN: Broadman & Holman Publishers.

Carson, D. A., France, R. T., Motyer, J. A., & Wenham, G. J. (Eds.). (1994). *New Bible commentary: 21st century edition* (4th ed.). Leicester, England; Downers Grove, IL: Inter-Varsity Press.

Dockery, D. S. (1998). The Pauline Letters. (D. S. Dockery, Ed.) *Holman concise Bible commentary*. Nashville, TN: Broadman & Holman Publishers.

Lucas, R. C. (1980). *Fullness & freedom: the message of Colossians & Philemon*. Downers Grove, IL: InterVarsity Press.

McNaughton, I. S. (2006). *Opening up Colossians and Philemon*. Leominster: Day One Publications.

Vaughan, C. (1981). Colossians. (F. E. Gaebelein, Ed.) *The Expositor's Bible Commentary: Ephesians through Philemon*. Grand Rapids, MI: Zondervan Publishing House.

Wiersbe, W. W. (1992). *Wiersbe's expository outlines on the New Testament*. Wheaton, IL: Victor Books.

Wright, N. T. (1986). *Colossians and Philemon: an introduction and commentary* (Vol. 12) Nottingham, England: Inter-Varsity Press.